សុន្ទរកថារបស់ **ទ៉ាដា តាកាយូគី**

លេខា ផ្នែកសហប្រតិបត្តិការសេដ្ឋកិច្ច និងជំនួយអភិវឌ្ឍន៍ផ្លូវការ

ស្ថានទូតជប៉ុនប្រចាំព្រះរាជាណាចក្រកម្ពុជា

ថ្លែងក្នុងពិធីសម្ពោធអគារសិក្សានៅសាលាបឋមសិក្សាបឹងត្នោត ក្នុងស្រុកបាកាន ខេត្តពោធិ៍សាត់

ថ្ងៃទី ២១ ខែកក្កដា ២០១៥

- សូមក្រាបថ្វាយបង្គំ ព្រះថេរានុត្ថេរៈគ្រប់ព្រះអង្គ
- សូមគោរព **ឯកឧត្តម ហៀង ស៊ីណេ** អនុរដ្ឋលេខាធិការក្រសួងអប់រំ យុវជន និងកីឡា
- សូមគោរព **ឯកឧត្តម ម៉ក់ វ៉ា** អភិបាលរងនៃគណៈអភិបាលខេត្តពោធិ៍សាត់
- សូមគោរព **លោក សួន សុភី** ប្រធានមន្ទីរអប់រំ យុវជន និងកីឡាខេត្តពោធិ៍សាត់
- សូមគោរព ឯកឧត្តម លោកជំទាវ អស់លោក លោកស្រីជាភ្ញៀវកិត្តិយសទាំងអស់!

ខ្ញុំមានសេចក្តីសោមនស្សរីករាយយ៉ាងខ្លាំង ដែលបានមកចូលរួមក្នុងពិធីសម្ពោធអគារសិក្សាថ្មីនៅសាលាបឋមសិក្សាបឹងត្នោតនៅថ្ងៃនេះជាមួយនឹងវត្តមានដ៏ឧត្តុងឧត្តមរបស់**ឯកឧត្តម ហៀង ស៊ីណេ** អនុរដ្ឋលេខាធិការក្រសួងអប់រំ យុវជន និងកីឡា និង**ឯកឧត្តម ម៉ក់ វ៉ា** អភិបាលរងនៃគណៈអភិបាលខេត្តពោធិ៍សាត់។ ជាបឋម ខ្ញុំសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះក្រសួងអប់រំ យុវជន និងកីឡា និងជាពិសេស អង្គការ VAPSD ដែលបានផ្តួចផ្តើមគំនិត និងអនុវត្តគម្រោងនេះយ៉ាងសកម្មកន្លងមក។

ការធានានូវការទទួលបានការអប់រំកម្រិតបឋមសិក្សា គឺមានសារៈសំខាន់ណាស់សម្រាប់សិស្សានុសិស្សទាំងអស់នៅទូទាំងប្រទេសកម្ពុជា ដើម្បីកសាងមាគាអប់រំរបស់ពួកគេឆ្ពោះទៅដល់កម្រិតមធ្យមសិក្សាបឋមភូមិ។ ខ្ញុំសូមសម្តែងនូវការគោរពដោយស្មោះសរចំពោះការប្តេជ្ញាចិត្ត និងកិច្ចខិតខំប្រឹងប្រែងរបស់រាជរដ្ឋាភិបាលកម្ពុជាក្នុងការកែលម្អវិស័យអប់រំ។ ដោយទទួលស្គាល់ពីសារៈសំខាន់នៃការកែលម្អបរិស្ថានអប់រំ ជាកត្តាគន្លឹះសម្រាប់ការអភិវឌ្ឍធនធានមនុស្សអោយបានជោគជ័យនោះ រដ្ឋាភិបាលជប៉ុន បាននឹងកំពុងបន្តផ្តល់ជំនួយឧបត្ថម្ភរបស់ខ្លួន ដើម្បីគាំទ្រដល់កិច្ចខិតខំប្រឹងប្រែងរបស់រាជរដ្ឋាភិបាលកម្ពុជាតាមរយៈការជួយសាងសង់សាលារៀនក៏ដូចជាបណ្តុះបណ្តាលគ្រូបង្រៀនជាដើមតាំងពីកំឡុងទសវត្សឆ្នាំ១៩៩០មកម្ល៉េះ។

អង្គការ VAPSD បាននឹងកំពុងរួមចំណែកយ៉ាងសកម្មក្នុងការសាងសង់អគារសិក្សានៅក្នុងខេត្តពោធិ៍សាត់ ហើយសាលារៀនថ្មីនេះ ជាសាលាបឋមសិក្សាទី៥ហើយដែលបានសាងសង់ដោយគម្រោងជំនួយឧបត្ថម្ភជប៉ុនសម្រាប់ទ្រង់ទ្រាយតូច។ ខ្ញុំបានទទួលដំណឹងថាសិស្សានុសិស្សប្រមាណជា៤៣០នាក់ នៅសាលាបឋមសិក្សាបឹងត្នោតនេះ ត្រូវរៀននៅក្នុងអគារសិក្សាដែលមានសភាពចាស់ទ្រុឌទ្រោមខ្លាំង ឬក៏ត្រូវរៀននៅក្រៅថ្នាក់រៀនទៀតផង ដោយសារតែកង្វះខាតនៃបន្ទប់រៀន។ គម្រោងនេះ បានផ្តល់នូវអគារសិក្សាចំនួនមួយខ្នងមាន៦បន្ទប់ រួមជាមួយបរិក្ខាសិក្សា បន្ទប់អនាម័យ និង ធុងស្តុកទឹកមួយ។ ខ្ញុំបានទទួលពត៌មានថា សិស្សចំនួន៥០នាក់ បានចូលមករៀនវិញ បន្ទប់ពីសាងសង់អគារនេះរួចមក។

ខ្ញុំសង្ឃឹមថា សិស្សានុសិស្សទាំងអស់នៃសាលាបឋមសិក្សាបឹងត្នោតនេះនឹងអាចធ្វើការសិក្សានៅក្នុងអគារសិក្សា ដែលមានបរិស្ថានប្រកបដោយសុវត្ថិភាព និងផាសុខភាព។ ដូច្នេះសូមក្មួយៗសិស្សានុសិស្សជួយថែរក្សាអគារសិក្សាថ្មីនេះអោយបានគង់វង្សល្អ ដើម្បីទុកជានិមិត្តរូបដ៍យូរអង្វែងមួយនៃទំនាក់ទំនងរវាងមិត្តភាពរវាងប្រទេសជប៉ុន និងព្រះរាជាណាចក្រកម្ពុជា។

ជាចុងក្រោយនេះ ខ្ញុំសូមសម្តែងនូវការកោតសរសើរដោយស្មោះសរចំពោះលោក-អ្នកទាំងអស់ដែលបានរួមចំណែកធ្វើអោយគម្រោងនេះដំណើរការទៅបានដោយរលូន។ ខ្ញុំសង្ឃឹមយ៉ាងមុតមាំថា កិច្ចសហប្រតិបត្តិការនេះ នឹងជួយពង្រឹងជាបន្តទៅទៀតនូវទំនាក់ទំនងមិត្តភាពរវាងប្រជាជនជប៉ុន និងប្រជាជនកម្ពុជា។

**សូមអរគុណចំពោះការយកចិត្តទុកដាក់ស្តាប់!**